# គុកលិច (ប្រាសាទត្នោតជុំខាងលិច)

គុកលិច គឺជាឈ្មោះដែលអ្នកស្រុកហៅសព្វថ្ងៃ ដ្បិត គុក គឺមានន័យថា "ប្រាសាទ" ហើយ លិច គឺសំដៅលើប្រាសាទនេះស្ថិតនៅទិសខាងលិចភូមិ។ លោក Étinne Aymonier ហៅប្រាសាទនេះថា "តាកែវ" តែសព្វថ្ងៃឈ្មោះនេះមិនមាននរណាស្គាល់ឡើយ។[១] ចំណែក លោក Lunet De Lajonquière ហៅប្រាសាទនេះថា "ត្នោតជុំ"។[២] គុកលិច មានទីតាំងស្ថិតនៅភូមិត្នោតជុំទី៣ ឃុំត្នោតជុំ ស្រុកបារាយណ៍ ខេត្តកំពង់ធំ។ កន្លងមកមានអ្នកស្រាវជ្រាវជាតិ និងអន្តរជាតិជាច្រើនធ្លាប់មកសិក្សាស្រាវជ្រាវនៅប្រាសាទនេះ។ គុកលិច សង់ឡើងអំពីឥដ្ឋ មានរាងបួនជ្រុងស្មើ បែរមុខទៅទិសខាងជើង និងមានស្នាកស្នាមគូទឹកនៅទិសឦសាន។ ជាទូទៅប្រាសាទដែលបែរមុខទៅទិសខាងជើងមានមិនសូវច្រើនប៉ុន្មានទេ តែគេធ្លាប់ឃើញមាននៅភ្នំដា សំបូរព្រៃគុក ។ល។ លោក Lunet De Lajonquière យល់ថា គុកលិច គឺជាប្រាសាទឥដ្ឋនៅស្រុកខ្មែរដែលនៅរូបរាងល្អជាងគេ (រូបលេខ១-៣)។[៣]

ប្រាសាទនេះ សង់ឡើងជាប្រាសាទទោលមានបួនថ្នាក់។ ថ្នាក់នីមួយៗមិនសូវមានចម្លាក់អ្វីច្រើននៅលើជញ្ជាំងប្រាសាទដូចនៅគុកជើងក្បែរនោះទេ ពោលមានតែចម្លាក់លម្អជាទ្វារបញ្ឆោតដែលមានរាងខ្ពស់ទ្រវែងគ្រប់ថ្នាក់ទាំងអស់។ ទម្រង់របៀបនេះ យើងជួបប្រាសាទច្រើននៅស.វ.ទី១០។ ក្រៅពីនេះ គឺមានតែការលម្អជាសសរផ្អោប និងហោជាងរាងទ្រនង់នាគប៉ុណ្ណោះ។ ខឿនប្រាសាទ គេរៀបថ្នាក់ៗជាសារពើសូត្រ ដែលការលម្អរបៀបនេះមានទម្រង់ដូចក្បាច់នៅសម័យមុនអង្គរដែរ។ ថ្វីត្បិតតែគុកលិចសាងអំពីឥដ្ឋក៏ពិតមែនតែគ្រឿងលម្អស្ថាបត្យកម្មសុទ្ធសឹងធ្វើឡើងអំពីថ្មភក់ ដូចជា ទ្វារ, ផ្តែរ, កំពូល, សសរពេជ្រ, បល្ល័ង្ក។ ផ្តែរទ្វារគុកលិច ទើបនឹងជ្រុះធ្លាក់មកក្រោមប្រមាណ ២០ឆ្នាំមុន តែក្បាច់លម្អនៅរក្សាទម្រង់ដើមយ៉ាងល្អប្រណីត។ ផ្នែកខាងលើនៃផ្តែរគេលម្អដោយរូបទេពនៅក្នុងក្បាច់សន្ទឹកដែលមានចំនួនសរុប២៤អង្គ។ នៅត្រង់ផ្នែកកណ្តាល គេឆ្លាក់រូបព្រះឥន្ទ្រគង់លើដំរីឰរ៉ាវតមានក្បាលមួយ និងនៅអមដំរីមានរូបតោឈរចំនួនពីរខ្ជាក់ឬលេបក្បាច់បន្ទាត់ផ្ចូរាងជាមែកឈើឬទំពក់កោងបន្តិច។ នៅខាងចុងសងខាងក្បាច់បន្ទាត់ផ្ចូ មានឆ្លាក់រូបសត្វមករខ្ជាក់សត្វតោ ព្រមទាំងមានក្បាច់ចង្វាយអង្គរឆ្លាស់គ្នាយ៉ាងប្រណីតបំផុត។ ក្បាច់លម្អនៃផ្តែរនេះ មានទម្រង់ជាសិល្បៈរចនាបថប្រែរូប នាស.វ.ទី១០ នៅក្នុងរជ្ជកាលព្រះបាទរាជេន្ទ្រវរ្ម័ន

---

[១] Aymonier 1900: 352.

[២] Lajonquière 1901: 210.

[៣] Lajonquière 1901: 210.

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

(គ.ស.៩៤៤-៩៦៧) (រូបលេខ៤)។[៤]

នៅគុកលិច គេធ្លាប់រកឃើញថ្មគោលមានមុខបួន ដែលមានចារឹកអក្សរគ្រប់ទិសទាំងអស់ ហើយលោក Étinne Aymonier ធ្លាប់បានរៀបរាប់ខ្លះៗនៅក្នុងអត្ថបទរបស់លោកកាលពីឆ្នាំ ១៩០០។[៥] ក្រោយមក លោក George Coedès ក៏បានបកប្រែម្តងទៀតនៅឆ្នាំ ១៩៥៤។[៦] ប៉ុន្តែ គួរឱ្យសោកស្តាយគោលចារឹកមុខបួននេះបានបាត់បង់ទៅហើយ។ គោលចារឹកនេះ ចុះបញ្ជីលេខ K.143 ចារឹកជាភាសាខ្មែរបុរាណ ដែលមុខ "ក" មានចំនួន ២៧បន្ទាត់, មុខ "ខ" មានចំនួន ២៥បន្ទាត់, មុខ "គ" មានចំនួន ២៥បន្ទាត់ និងមុខ "ឃ" មានចំនួន២២បន្ទាត់។ សិលាចារឹកនេះ ទំនងគេចារឹកឡើងមកតម្កល់នៅប្រាសាទពុំមែនពេលតំណាលគ្នានោះទេ។ ពោល គឺទំនងប្រាសាទសាងឡើងនៅក្នុងរជ្ជកាលព្រះបាទរាជេន្ទ្រវរ្ម័ន (គ.ស.៩៤៤-៩៦៧) ប៉ុន្តែសិលាចារឹកអាចមានអាយុកាលនៅក្នុងរជ្ជកាលព្រះបាទជ័យវីរវរ្ម័ន (គ.ស.១០០២-១០០៦)។ លក្ខណៈរបៀបនេះ យើងជួបនៅប្រាសាទអំបែងនំដូចគ្នា ពោល គឺប្រាសាទសង់រាជេន្ទ្រវរ្ម័ន តែសិលាចារឹករជ្ជកាលព្រះបាទជ័យវីរវរ្ម័ន។ ខ្លឹមសារសិលាចារឹកគុកលិចនេះរៀបរាប់អំពី អ្នកសញ្ជកម្នាក់ (មេទ័ព) បានចារគោលចារឹកមួយមុខបួនរៀបរាប់រឿងរ៉ាវបោះបង្គោលព័ទ្ធដីមួយកន្លែងនៅព្រៃរំដេង។ ដីនៅព្រៃរំដេង ជាដីដែលមន្ត្រីម្នាក់មានងារជា "ម្រតាញ" បានស្នើសុំពីព្រះមហាក្សត្រយកទៅធ្វើជាជង្វាយដល់កម្រតេងជគតលិង្គបុរ និងកន្ទោងកម្រតេងអញអង្វើទន្វេ តាំងពីរជ្ជកាលព្រះបាទរាជេន្ទ្រវរ្ម័ន។ បន្ទាប់ពីព្រះរាជាបានប្រទានហើយ ទ្រង់បានចាត់តាំងមន្ត្រីចំនួនបួននាក់មាននាម លោញរេស លោញរាជទាស វាបគោត និងវាប.....ជាអ្នកទៅបោះបង្គោលដីនោះ ហើយកិច្ចការថ្វាយដីនេះទៅទីសាសនដ្ឋានទ្រង់បានចាត់តាំងឱ្យមន្ត្រីឈ្មោះ វាបវុ និងស្តេងបរមចាយ៉្យចាត់ចែង។ ក្រោយមក នៅរជ្ជកាលស្តេចជ័យវរ្ម័នទី៥ ព្រះរាជគ្រូបានទូលព្រះរាជាថា មន្ត្រីជាន់មុនពុំទាន់បានបោះបង្គោលដីនៅព្រៃរំដេងបានចប់សព្វគ្រប់តាមព្រះរាជបញ្ជាស្តេចអង្គមុននៅឡើយទេ។ ព្រះបាទជ័យវរ្ម័នទី៥ ទ្រង់ក៏បញ្ជាមន្ត្រីឈ្មោះ លោញហិតគត និងថៅហ្វាយស្រុកទៅព័ទ្ធដីនោះម្តងទៀត។ បន្ទាប់ពីបោះបង្គោលដីរួចរាល់ ទ្រង់បានចាត់តាំងឱ្យអស់ពួកមន្ត្រីមួយចំនួននាំគ្នាកសាងជាអាសន (ទេវស្ថាន) នៅទីនោះ។ លុះមកដល់រជ្ជកាលព្រះបាទជ័យវីរវរ្ម័ន ទ្រង់បានបញ្ជាឱ្យគេកសាងគោលចារឹកឡើងដោយបានប្រទានពរជ័យអ្នកដែលធ្វើឱ្យទេវស្ថានចម្រុងចម្រើន និងដាក់បណ្តាសាអ្នកដែលមិន

[៤] Boisselier, 1966: 152.

[៥] Aymonier, 1900: 352.

[៦] Coedès, 1954: 218.

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

គោរពទេវស្ថាននេះ។ ទ្រង់ក៏បានមានព្រះរាជបន្ទូលថា បង្គោលដីនៅព្រៃរំដេងដែលបាត់ទាំងអម្បាលម៉ាន អ្នកពាក់ព័ន្ធត្រូវធ្វើឡើងវិញ ដើម្បី.....។

ជារួមមក គុកលិច ឬហៅថាប្រាសាទត្នោតជុំខាងលិច ទំនងប្រាសាទសាងឡើងនៅក្នុងរចនាបថប្រែរូប នាស.វ.ទី១០ ក្នុងរជ្ជកាលព្រះបាទរាជេន្ទ្រវរ្ម័ន (គ.ស.៩៤៤-៩៦៧) ឧទ្ទិសដល់ព្រហ្មញ្ញសាសនា។ ប៉ុន្តែ នៅក្នុងរជ្ជកាលព្រះបាទជ័យវីរវរ្ម័ន (គ.ស.១០០២-១០០៦) ទ្រង់បានបញ្ជាឱ្យអ្នកសញ្ជកម្នាក់យកគោលចារឹកមកតម្កល់នៅក្នុងប្រាសាទ។ ប្រការមួយគួរចាប់អារម្មណ៍ខ្លាំងនោះគឺ នៅខាងត្បូងគុកលិចមានសំណង់មួយលើកខ្ពស់ផុតពីដីប្រហែល ១ម៉ែត្រ សាងឡើងអំពីថ្មបាយក្រៀម រាងបួនជ្រុងទ្រវែង មានបណ្តោយ១៥ម៉ែត្រ, ទទឹង៨ម៉ែត្រ និងមានសន្ទឹកសីមា។ សំណង់នេះ ទំនងជាឧបោសថាគារនៃព្រះពុទ្ធសាសនាថេរវាទនៅសម័យក្រោយ។ នៅប្រាសាទនេះ មិនមានការកែច្នៃជារូបព្រះពុទ្ធនៃលទ្ធិព្រះពុទ្ធសាសនាថេរវាទដូចនៅគុកជើងក្បែរនោះទេ។ អ្នកស្រុកដែលរស់នៅទីនោះ ចងចាំគ្រប់គ្នាថា នៅបរិវេណគុកលិច គឺជាវត្តចាស់ដែលពួកគាត់តែងមកធ្វើពិធីបុណ្យរៀងរាល់ឆ្នាំ ហើយក្រោយមកមានជនខិលខូចមកជីកកកាយរកវត្ថុបុរាណនៅទីនោះច្រើនដងពេក ពួកគាត់ក៏ឈប់ទៅធ្វើបុណ្យនៅទីនោះទៀតទៅ។

## ឯកសារយោង

**Aymonier, Etienne**
1900, *Le Cambodge: Le Royaum Actuel*. Paris. Ernest Leroux.
**Boisselier, Jean**
1966, "*Asie du Sud-Est, Le Cambodge* ", Tome I, Paris
**Coedès, George**
1964, *Inscription du Cambodge*, Vol VII, Hanoi
**Lunet De Lajonquière**
1902, *Inventaire descriptive des monuments du Cambodge*, Tome I, Paris

អត្ថបទដោយ៖ ម៉ង់ រ៉ាលី



រូបទី១៖ គុកលិច មើលពីមុខខាងជើង (រូបថត៖ កុំ រតនៈពិសិដ្ឋ)



រូបទី២៖ គុកលិច មើលពីមុខអាគ្នេយ៍ (រូបថត៖ កុំ រតនៈពិសិដ្ឋ)

អត្ថបទដោយ៖ ម៉ង់ រ៉ាលី



រូបទី៣៖ គុកលិច មើលពីមុខពាយព្យ (រូបថត៖ កុំ រតនៈពិសិដ្ឋ)



រូបទី៤៖ ផ្តែរទ្វារគុកលិច (រូបថត៖ កុំ រតនៈពិសិដ្ឋ)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី